ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៦៩ សណ ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពទឹកជំនន់ទន្លេមេគង្គ និងជំនន់ស្ទឹងសែន

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា : ដោយសារការធ្លាក់ភ្លៀងយ៉ាងខ្លាំងនៅក្នុងអាងទន្លេមេគង្គក្នុងប្រទេសថៃ និងប្រទេសឡាវ ក៏ដូចជានៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា នាពេលកន្លងមក បានធ្វើឱ្យកំពស់ទឹកទន្លេមេគង្គ និងស្ទឹងមួយចំនួនក្នុងប្រទេសកម្ពុជា ពិសេសស្ទឹងសែន បានហក់ឡើងយ៉ាងលឿន បង្កជាជំនន់ ធ្វើឱ្យមានការប៉ះពាល់ដល់បណ្តាខេត្តមួយចំនួន ។ មកដល់ថ្ងៃទី 11 ខែសីហា ឆ្នាំ 2014 នេះ ទឹកជំនន់នៅខេត្តស្ទឹងត្រែង និងខេត្តក្រចេះ បានស្រកផុតពីកម្រិតកំពស់ដែលត្រូវប្រកាសឱ្យមានការប្រុងប្រយ័ត្នហើយ ប៉ុន្តែ ស្ថានភាពជំនន់នឹងបង្កផលប៉ះពាល់ដល់បណ្តាខេត្តមួយចំនួននៅតាមដងទន្លេមេគង្គក្រោម ទន្លេបាសាក់ និងទន្លេសាប ។ ទន្ទឹមនឹងនេះ ទឹកជំនន់ស្ទឹងសែន ដែលបានស្រកចុះពីខេត្តព្រះវិហារ ក៏ធ្វើឱ្យមានការប៉ះពាល់ដល់ខេត្តកំពង់ធំ ផងដែរ ។ ការពិនិត្យលើកំពស់ទឹក នៅតាមបណ្តាទន្លេ និងស្ទឹងនានា បានបង្ហាញថា :

- **ទឹកទន្លេមេគង្គក្រោម និងទន្លេបាសាក់ :** ទឹកកំពុងបន្តហូរចូលតាមតំបន់ទំនាបលិចទឹកនានា នៃខេត្តព្រៃវែង កណ្តាល និងខេត្តតាកែវ ។ តំបន់ទំនាបទាំងនេះ ប្រឈមនឹងការលិចលង់ក្នុងរយៈពេលមួយសប្តាហ៍ទៀត ។
- **ទឹកជំនន់ស្ទឹងសែន :** មកដល់ព្រឹកថ្ងៃទី 11 ខែសីហា ឆ្នាំ 2014 នេះ ទឹកស្ទឹងសែន នៅខេត្តព្រះវិហារ មានកំពស់ 11,76 m ឯទឹកស្ទឹងសែននៅខេត្តកំពង់ធំ មានកំពស់ 13,53 m ទាបជាងកម្រិតប្រុងប្រយ័ត្ន តែ 0,07m ប៉ុណ្ណោះ ។ និយាយជារួម ទឹកស្ទឹងសែននៅខេត្តព្រះវិហារនឹងបន្តស្រកចុះ ប៉ុន្តែទឹកស្ទឹងសែននៅខេត្តកំពង់ធំនឹងបន្តកើនឡើងហួសពីកម្រិតប្រកាសឱ្យមានការប្រុងប្រយ័ត្ន ។ម្យ៉ាងវិញទៀត ដោយសារទឹកបឹងទន្លេសាបខ្ពស់ និងបន្តកើនឡើងជារៀងរាល់ថ្ងៃផងនោះ ធ្វើឱ្យទឹកស្ទឹងសែនហូរចុះ និងស្រកយឺត ។ ការលិចលង់ នឹងបន្តរយៈពេលយូរ ( ក្នុងអំឡុងពេលពី 07 ទៅ 10 ថ្ងៃ ខាងមុខ ) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គក្រោម ទន្លេសាប ទន្លេបាសាក់ និងស្ទឹងសែន សូមមានវិធានការណ៍ និងបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់បំផុត ចំពោះស្ថានភាពទឹកជំនន់ខាងលើនេះ ដើម្បីចៀសវាងនូវគ្រោះផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម_គានហោ


អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥

# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh